**ប្រការ ២ ថ្មី** : សាខាមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា - ជប៉ុន ជាអង្គភាពចំរុះមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា–ជប៉ុន ។

**ប្រការ ២** : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ មានភារកិច្ចរៀង ៗ ខ្លួន អនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាហាន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៧០ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ខ្វារ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ ខែ ១១ ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។
- បានឃើញអនុក្រឹត្យ លេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា ។

– បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម លេខ ៣៩១ អ្នយក.បថ.មត្ត ចុះថ្ងៃទី ០៥ ធ្នូ ឆ្នាំ ១៩៩៥ ។

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកំពង់ចាមប្តូរឈ្មោះ សាលាបឋមសិក្សាខ្នារ នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្ត កំពង់ចាម មកជា សាលាបឋមសិក្សា **ស ខេង ខ្នារ** ចាប់ពីឆ្នាំសិក្សា ១៩៩៥–១៩៩៦ នេះតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** មន្ទីរក្រសួងអប់រំយុវជន និង កីឡា នាយកដ្ឋានចាត់តាំងនាយកដ្ឋានផែនការហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម ការិយាល័យអប់រំយុវជន និង កីឡា ស្រុកត្បូងឃ្មុំ សាលាបឋមសិក្សា **ស ខេង ខ្នារ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**តា សាហាន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៧៥ អយក.ប្រក**

**ស្តីពីការទទួលស្គាល់ និង ការប្រគល់វិញ្ញាបនបត្រ នៃការប្រឡង**

**សញ្ញាបត្រ មធ្យមសិក្សាកម្រិត ១**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**